# នរកក្នុងជំនឿ

សាសនាដទៃក្នុងលោកតែងបរិយាយរៀបរាប់អំពីនរក និងសួគ៌ ហើយជំនឿនេះគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងកម្មដែលមនុស្សបានប្រព្រឹត្តិកាលនៅរស់។ សម្រាប់ស្រុកខ្មែរដែលមានជំនឿតាមព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសានាផង គេជឿថាក្រោយពេលមនុស្សណាម្នាក់ស្លាប់ទៅ ព្រលឹងអ្នកនោះនឹងត្រូវនាំយកទៅនរក១៥ថ្ងៃ[១] ដោយយម្ភបាលដែលជាអ្នករក្សានរក ដើម្បីឲ្យព្រះយមរាជវិនិច្ឆ័យទោស (រូបលេខ១)។ ក្រោយការវិនិច្ឆ័យទោសកំហុសហើយ ព្រលឹងអ្នកនោះអាចឡើងទៅស្ថានសួគ៌ ឬនឹងត្រូវចាប់កំណើតជាថ្មីប្រសិនបើគេធ្វើកម្មល្អ។ ប៉ុន្តែបើគេធ្វើកម្មអាក្រក់ គេនឹងធ្លាក់នរកតាមកំរិតបាបដែលគេបានប្រព្រឹត្តិ[២] (រូបលេខ២)។ តើនរកមានប៉ុន្មានជាន់ និងទណ្ឌកម្មយ៉ាងណា?

ក្នុងជំនឿបែបព្រះពុទ្ធសាសនា គេជឿថានរកទាំងអស់មានចំនួន៣២ជាន់ ហើយក្នុងចំណោមនរកទាំងនេះមាននរកធំចំនួន៨។ អ្នកដែលធ្លាក់នរកនេះ គឺបានប្រទូស្តរាយនឹងអ្នកបួស ខ្វះជាជនកំណាចឃោរឃៅដែលបានសំលាប់ឪពុកម្តាយជាដើម។[៣] នរកធំៗទាំង៨នេះមានដូចជា[៤]៖

**សញ្ជីវៈ** (នរកដែលមានជីវិត ឬនរកដែលរស់ឯង) នរកនេះមានអាយុ៥០០ឆ្នាំ ដែល១ថ្ងៃ១យប់ស្មើនឹង ៩០០០០ឆ្នាំមនុស្ស ដូច្នេះ៥០០ឆ្នាំនរក ស្មើនឹង ១៦២០ ០០០ ០០០ ០០០ឆ្នាំមនុស្ស។

**កាឡសុត្តៈ** (នរកខ្សែបន្ទាត់ដែក) មានអាយុកាល១០០០ឆ្នាំ ដែល១ថ្ងៃ១យប់ស្មើនឹង៣៦លានឆ្នាំមនុស្ស ដូច្នេះ១០០០ឆ្នាំ ស្មើនឹង១២ ៩៦០ ០០០ ០០០ ០០០ឆ្នាំមនុស្ស។

**សង្ឃាតៈ** (នរកសង្កត់កំទេច) នរកនេះមានអាយុកាល២០០០ឆ្នាំ។ ១ថ្ងៃ១យប់ស្មើនឹង ១៤៥ លានឆ្នាំមនុស្ស ដូច្នេះ២០០០ឆ្នាំ ស្មើនឹង១០៣ ៦៨០ ០០០ ០០០ ០០០ឆ្នាំមនុស្ស។

**រោរវៈ** (ស្រែកយំដោយអណ្តាតភ្លើង) នរកនេះមានអាយុកាល៤០០០ឆ្នាំ ហើយ១ថ្ងៃ១យប់ស្មើនឹង៥៧ ៦០០ ០០០ឆ្នាំមនុស្ស ដូច្នេះ៤០០០ឆ្នាំ គឺស្មើនឹង ៨៣៩ ៤៤០ ០០០ ០០០ ០០០០០ឆ្នាំមនុស្ស (រូបលេខ៣)។

---

[១] វ៉ា អ៊ុណារិទ្ធ២០០៤:៦
[២] Jens Braarvig 2009: 254
[៣] Ibit
[៤] G.Coedès 1973: 30

អត្ថបទដោយ៖ មាស សុភាព

**មហារោរវៈ** (ស្រែកយំដោយផ្សែងភ្លើង) នរកនេះមានអាយុ៨០០០ឆ្នាំ ហើយ១ថ្ងៃ១យប់ស្មើនឹង ២៣០ ៤០០ ០០០ឆ្នាំមនុស្ស ដូច្នេះ៨០០០ឆ្នាំ គឺស្មើនឹង ៦ ៦៣៥ ៥២០ ០០០ ០០០ ឆ្នាំមនុស្ស (រូបលេខ៦)។

**តបនៈ** (នរកដែកក្ដៅ) នរកនេះមានអាយុ១៦០០០ឆ្នាំ ហើយ១ថ្ងៃ១យប់ស្មើនឹង ៩ ២១៦ ០០០ ០០០ឆ្នាំមនុស្ស ដូច្នេះ១៦០០០ឆ្នាំ គឺស្មើនឹង ៥៣ ០៨៤ ១៦០ ០០០ ០០០ ០០០ឆ្នាំមនុស្ស។

**មហាតបនៈ** (នរកដែកក្ដៅខ្លាំង) នរកនេះមានអាយុកាលមិនកំណត់ ដូច្នេះអ្នកដែលធ្លាក់ទៅនរកនេះគ្មានថ្ងៃនឹងបានចាប់កំណើតជាថ្មីទេ គឺគេកំណត់អាយុដោយកប្បថ្មីវិញ។[៥]

**អវិចី ឬមហាអវចី** (នរកដែលគ្មានកន្លែងជ្រកពួន) អ្នកដែលធ្លាក់នរកនេះគ្មានថ្ងៃចាប់ជាតិជាថ្មីឡើយ។ គ្រាន់តែអណ្ដាតភ្លើងដែលកាយចេញពីទិសទាំងបួនមានចំងាយ១០០យោជន៍។ នរកនេះវាស់ត្រង់កណ្ដាលបាន៣១៨យោជន៍ ហើយវាស់ជុំវិញបាន៩៥៤យោជន៍ (រូបលេខ៥)។

ក្រៅពីនរកធំទាំង៨នេះ មាននរកមួយចំនួនផ្សេងទៀតដូចជាៈ លោហកុម្ភី (ខ្ទះទង់ដែង) គូថនរក (ជុំលាមក) កុក្កុលនរក (នរកផេះ) សិម្ពលីនរក (នរកដើមរកា) នរកអសិបត្ត (ស្លឹកដាវ) នរកខោទកៈ (ឬស្ទឹងវេតករណី) នរកសុនខ (សត្វឆ្កែ) នរកអយបថវី (ផែនដីដែកក្រហម) អង្គារកាសុនរក (រងើកភ្លើង) អយោទកនរក (ទឹកដែកក្រហម) ថុសនរក (អង្កាម) អយសូលនរក (ចំរូងដែក) សញ្ជោតិនរក (អាវុធដែកក្រហម) កូដកាវីនរក (មនុស្សកោង) អយប័ព្វតនរក (ភ្នំដែក) ផលិតអង្គាមនរក (រណ្ដៅរងើកភ្លើង) មិច្ឆាទិដ្ឋកនរក (លោកន្ទរ ឬអន្តរ) នរកសុរដ្ឋាតិ (រងើកភ្លើង) ធុសាបលចៈ (នរកទឹក) ជាដើម។

ចំពោះនរកបែបព្រហ្មញ្ញសាសនាដែលមាននៅក្នុងស្រុកខ្មែរ បង្ហាញឡើងលើចម្លាក់ក្រឡោតទាបទៅលើថែវខាងត្បូងរបស់ប្រាសាទអង្គរវត្ត។ ផ្ទាំងចម្លាក់នេះមិនមែនបង្ហាញត្រឹមតែឈ្មោះរបស់នរកទាំង៣២[៦]ទេ ប៉ុន្តែក៏បង្ហាញរបៀបនៃការធ្វើទារុណកម្មក្នុងនរក

[៥] វ៉ា អ៊ីណារិទ្ធ២០០២:៨

[៦] Saveros Pou 1996: 163-168

ទាំងនោះផងដែរ។ ប៉ុន្តែអាស្រ័យដោយផ្នែកខ្លះបានរលុបខូចខាត បណ្ដាលឲ្យឈ្មោះទាំង៣២មិនអាចកំណត់បានទាំងស្រុងនោះទេ។ នរកទាំងនោះមានឈ្មោះដូចជា៖ អវចី (ឋានគ្មានរលក) ក្រិមិនិចយៈ (ដែលមានគំនរដង្កូវ) វៃតរណីទី (ស្ទឹងវៃតរណី) កូដសលមលី (ព្រៃរកាដែលមានបន្លា) យុគមបវ៉ត (នរកភ្នំក្ដោះ) និរុចឆ្វាស (ដែលគ្មានដង្ហើម) ឧចឆ្វាស (ដកដង្ហើមធំ) ទ្រវះត្រពុ (ឋានសំណររាវ) គបួលាក្សមយ (ខ្ទុកខ្មៅ) អស្ថិកង្គ (បំបែកឆ្អឹង) ក្រុះកចឆេទ (នរកដែលគេអារ) បូយបណ៌ហរទ (នរកពោរពេញដោយខ្ទុះ) អស្រិកបូណ៌ហរទ (នរកទឹកភ្នែក) មេទោហរទ (នរកខ្លាញ់) (រូបភាពទី៦) ត័ក្សណាយសុទ្ធ (ដែលមានមាត់បូញស្រួច) អង្គារនិចយៈ (គំនររងើកភ្លើង) អមារីស (ខ្វះខ្លាញ់) កុមីបាក (ឋានដុតឆ្នាំង) កាលព្រឹក្សវរ (នរកដែលមានដើមត្នោត) ក្សុរធារបវ៉ត (នរកពោរពេញដោយបន្ទារ) សាន់តបនៈ (ក្ដៅក្រហាយ) សុចិមុខ (ច្របូចដូចម្ជុល) កាលសូត្រៈ (នរកខ្សែខ្មៅ) មហាបទម (នរកផ្កាឈូកធំ) បទម (នរកដែលមានផ្កាឈូក) សញ្ជីវន (នរកមានជីវិត) សិតៈ (នរកត្រជាក់) សាន្ទ្រតមៈ (នរកងងឹត) មហារោរវ និងរោរវ។

ដោយឡែកគេមិនបានដឹងប្រាកដជាចំនួន និងឈ្មោះនរកដែលបានធ្លាក់នៅលើចម្លាក់ក្រឡោតទាបនេះ ដកស្រង់ចេញពីគម្ពីរក្នុងព្រហ្មញ្ញសាសនាមួយណាឲ្យជាក់ប្រាកដនោះទេ។ នៅស្រុកឥណ្ឌាមានគម្ពីរសាសនាមួយចំនួនដែលបានបង្ហាញឈ្មោះ និងចំនួននរក ក៏ប៉ុន្តែគម្ពីរទាំងនោះមិនបានបរិយាយត្រូវគ្នាទាំងស្រុងចំពោះចំនួន និងឈ្មោះរបស់នរកឡើយ។ ឧទាហរណ៍ដូចជា គម្ពីរ អាគ្នីបុរាណ បង្ហាញនរកតែចំនួន៤ប៉ុណ្ណោះ។ រីឯគម្ពីរមួយចំនួនផ្សេងទៀតបង្ហាញនរកតែចំនួន៧។ ដោយឡែកគម្ពីរដែលមានភាពល្បីល្បាញដូចជា Manu Smriti និង Yajnavalkya Smriti បង្ហាញនរកចំនួន២១ដូចគ្នា ក៏ប៉ុន្តែលំដាប់លេខរៀង និងឈ្មោះនរកចំនួន៥មិនដូចគ្នានោះទេ។ ផ្ទុយទៅវិញ គម្ពីរ Bhagavata Purana, Vishnu Purana និង Devi Bhagavata Purana បង្ហាញនរកចំនួន២៨។ ក្នុងចំណោមគម្ពីរទាំង៣នេះ Vishnu Purana មិនបានរៀបរាប់អំពីរបៀបនៃការធ្វើទារុណកម្មនោះទេ។

នរកទាំង២៨ ក្នុងគម្ពីរ Bhagavata Purana គឺ:

Tamisra, Andhatamisra, Raurava, Maharaurava, Kumbhipaka, Kalasutra, Asipatravana, Sukaramukha, Andhakupa, Krimibhojana, Samdamsa, Taptasurmi, Vajrakantaka-salmali, Vaitarani, Puyoda, Pranarodha,

Visasana, Lalabhaksa, Sarameyadana, Avichi, Ayahpana, Ksharakardama, Raksogana-bhojana, Sulaprota, Dandasuka, Avata-nirodhana, Paryavartana and Suchimukha[៧].

នរកទាំង២៨ ក្នុងគម្ពីរ Devi Bhagavata Purana មានចំនួន៥ដែលខុសគ្នានឹង Bhagavata Purana គឺ: Taptasurmi, Ayahpana, Raksogana-bhojana, Avata-nirodhana, Paryavartana ជំនួសដោយឈ្មោះ Taptamurti, Apahpana, Raksogana-sambhoja, Avatarodha, Paryavartanataka.

នរកទាំង២៨ ក្នុងគម្ពីរ Vishnu Puranaគឺ:

Raurava, Shukara, Rodha, Tala, Visasana, Mahajwala, Taptakumbha, Lavana, Vimohana, Rudhirandha, Vaitaraní, Krimiśa, Krimibhojana, Asipatravana, Krishna, Lalabhaksa, Dáruńa, Púyaváha, Pápa, Vahnijwála, Adhośiras, Sandansa, Kalasutra, Tamas, Avichi, Śwabhojana, Apratisht́ha, Avichi (នរកមួយផ្សេងទៀត)[៨].

ដូច្នេះប្រសិនបើសាកល្បងប្រៀបធៀបឈ្មោះនរកទាំង៣២ នៅលើថែវខាងត្បូងប្រាសាទអង្គរវត្តទៅនឹងគម្ពីរ Bhagavata Purana និង Devi Bhagavata Purana គឺមានឈ្មោះដូចគ្នាចំនួន១១។ បើប្រៀបនឹងគម្ពីរ Vishnu Purana គឺមានឈ្មោះដូចគ្នាតែចំនួន៧ប៉ុណ្ណោះ។ ហេតុដូច្នេះចំនួន និងឈ្មោះនរកដែលលេចឡើងក្នុងសង្គមខ្មែរមិនប្រាកដថាយកចេញពីគម្ពីរណាមួយរបស់ឥណ្ឌានោះទេ។ ទន្ទឹមនឹងនេះ ដោយសារគម្ពីរសំខាន់ៗមួយចំនួននៅស្រុកឥណ្ឌាមិនបង្ហាញភាពស៊ីគ្នាទាំងស្រុងរវាងឈ្មោះ និងលំដាប់នរក នាំឲ្យសន្និដ្ឋានឈ្មោះនរកមួយចំនួនប្រហែលជាកំណត់ស្របតាមបរិបទនៃសង្គមខ្មែរ។

---

[៧] en.wikipedia.org: 2021

[៨] Ibit

អត្ថបទដោយ៖ មាស សុភាព

# បញ្ជីរូបភាព



រូបលេខ១ ព្រះយមវិនិច្ឆ័យទោស



រូបលេខ២ ព្រលឹងអ្នកស្លាប់ និងផ្លូវទៅស្ថានតាំង៣



រូបលេខ៣ ទណ្ឌកម្មនៅក្នុងនរកពោរវ

អត្ថបទដោយ៖ មាស សុភាព



រូបលេខ២៤ ទណ្ឌកម្មនៅនរកមហារោរវ



រូបលេខ២៥ ទណ្ឌកម្មនៅនរកអវចី



រូបលេខ២៦ ទណ្ឌកម្មនៅនរកខ្លាញ់

# ឯកសារពិគ្រោះ

រ៉ា អ៊ីណារិទ្ធ

២០០២. *ជំនឿលើឋានសួគ៌ និងឋាននរក.* មហាវិទ្យាល័យបុរាណវិទ្យា, ភ្នំពេញ។

G. Coedes et C. Archaimbault.

1973. *Les Trois Mondes (Traibhumi Brah Rvan).* Vol. LXXXIX, Paris.

Jens Braarvig.

(2009). “The Buddhist Hell: An Early Instance of the Idea?” *The Uses of Hell,* vol.56, No.2/3. 254-281

Saveros Pou.

1996. “Inscription d’Angkorwat: Nouvelles inscription du Cambodge” Tome II, EFEO.

https://en.wikipedia.org/wiki/Naraka_(Hinduism)